ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

តាងនាមប្រជារាស្ត្រខ្មែរ
សាលាដំបូងខេត្តត្បូងឃ្មុំ

សាលាដំបូងខេត្តត្បូងឃ្មុំ

តុលាការព្រហ្មទណ្ឌ
រឿងព្រហ្មទណ្ឌលេខ: ៥០៦
ថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០២១
សាលក្រម
លេខ: ៥៣១ -ង-
ថ្ងៃទី៣១ ខែសីហា ឆ្នាំ ២០២២

បានបើកសវនាការជាអសាធារណៈនៅថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២២ និងប្រកាសសាលក្រម នៅថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២២ មានសមាសភាពដូចខាងក្រោម:

ចៅក្រមជំនុំជម្រះ

លោក [redacted] ចៅក្រមសាលាដំបូងខេត្តត្បូងឃ្មុំ ជាប្រធានក្រុមប្រឹក្សា
លោក [redacted] ចៅក្រមសាលាដំបូងខេត្តត្បូងឃ្មុំ ជាចៅក្រមប្រឹក្សា
លោក [redacted] ចៅក្រមសាលាដំបូងខេត្តត្បូងឃ្មុំ ជាចៅក្រមប្រឹក្សា

តំណាងអយ្យការ

លោក [redacted] ព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងខេត្តត្បូងឃ្មុំ

ក្រឡាបញ្ជីសវនាការ

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តត្បូងឃ្មុំ

ដើម្បីជំនុំជម្រះលើជនជាប់ចោទ:

-ឈ្មោះ [redacted] **សូនីតា** ភេទស្រី កើតថ្ងៃទី១០ ខែមេសា ឆ្នាំ ២០០៣ (អាយុ ១៧ឆ្នាំ) ជនជាតិខ្មែរ ទីកន្លែងកំណើតភូមិ [redacted] ខេត្តកំពង់ចាម មានទីលំនៅភូមិទទួលពពេល ឃុំក្រឡា ស្រុកកំពង់សៀម ខេត្តកំពង់ចាម ឪពុកឈ្មោះ [redacted] **អាស** (រស់) ម្តាយឈ្មោះ [redacted] **សុជា** (រស់) ស្ថានភាពគ្រួសារ នៅលីវ ជាអនីតិជន (**ក្រៅឃុំ: ដីកាសម្រេចមិនឃុំខ្លួនលេខ ៤៤ ចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០២២**។

ជាប់ចោទពីបទ: រំលោភលើទំនុកចិត្ត ប្រព្រឹត្តនៅភូមិទន្លេបិទលើ ឃុំទន្លេបិទ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ កាលពីថ្ងៃទី០១ ខែមេសា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងបញ្ជត្តិឱ្យផ្តន្ទាទោសតាមមាត្រា ៣៩១ និងមាត្រា ៣៩២ នៃក្រមព្រហ្មទណ្ឌ។

- លោកស្រីមេធាវី [redacted] អាស័យដ្ឋាន ការិយាល័យប្រតិភូគណៈមេធាវី ប្រចាំសាលាដំបូងខេត្តត្បូងឃ្មុំ ជាមេធាវីការពារសិទ្ធិជនជាប់ចោទឈ្មោះ [redacted] **សូនីតា** ។

-**ដើមបណ្តឹងរដ្ឋប្បវេណី:** ឈ្មោះ [redacted] **វណ្ណា** ភេទប្រុស អាយុ ៣០ឆ្នាំ មានទីលំនៅភូមិបឹងកុក២ សង្កាត់បឹងកុក ក្រុងចំពង់ចាម ខេត្តកំពង់ចាម ។

បានឃើញ:

-របាយការណ៍លេខ ២៦៥/២១ ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០២១ របស់ស្នងការដ្ឋាននគរបាលខេត្តត្បូងឃ្មុំ ផែនការងារនគរបាលព្រហ្មទណ្ឌ ។

-ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ ៤៥៧ អយ.ក/២២ ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០២១ របស់តំណាងអយ្យការអមសាលាដំបូងខេត្តត្បូងឃ្មុំ

Scanned with CamScanner

-ដីកាសម្រេចមិនឃុំខ្លួន ឈ្មោះ [redacted] សូនីតា លេខ ៤៤ ចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងខេត្តត្បូងឃ្មុំ។

-ដីកាសម្រេចដាក់ជនត្រូវចោទឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ឈ្មោះ [redacted] សូនីតា លេខ ៤៥ ព្រ.ទ១ ចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងខេត្តត្បូងឃ្មុំ ។

-ដីកាសន្និដ្ឋានស្តាពរលេខ ២២១ អយ.ក/២២ ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០២២ របស់តំណាងអយ្យការអមសាលាដំបូងខេត្តត្បូងឃ្មុំ ។

-ដីកាដំណោះស្រាយបញ្ហានរឿងទៅជំនុំជម្រះលេខ ៧៩៣ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តត្បូងឃ្មុំ ។

-ដីកាសម្រេចចាត់តាំងចៅក្រមជំនុំជម្រះលេខ ៦៨២ /២០២២ ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២២ របស់ប្រធានសាលាដំបូងខេត្តត្បូងឃ្មុំ។

អង្គហេតុ

កាលពីអំឡុងឆ្នាំ២០១៧ ជនជាប់ចោទ**ឈ្មោះ [redacted] សូនីតា** បានចូលមកធ្វើការនៅ ក្នុងក្រុមហ៊ុនលក់ដីឡូត៍ សូ សេត ឯ.ក ដែលមានស្នាក់ការនៅភូមិទន្លេបិទលើ ឃុំទន្លេបិទ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ ដោយធ្វើការផ្នែកបេឡា ហើយជនជាប់ចោទ គឺជាអ្នកទទួលប្រាក់បង់រំលោះថ្លៃដីពីអតិថិជន។ ក្រោយមកក្រុមហ៊ុនមានការសង្ស័យពីការបាត់ទឹកប្រាក់ដែលអតិថិជនបានបង់ ហើយខាងក្រុមហ៊ុនក៏បានធ្វើការស្រាវជ្រាវរកឃើញថា មានអតិថិជន ចំនួន១៨ នាក់ ដែលបង់រំលោះថ្លៃទិញដីឡូត៍ពីក្រុមហ៊ុន តាមរយៈលេខទូរស័ព្ទរបស់ក្រុមហ៊ុន ចំនួន ០៣ខ្សែ ០៨៨ ៧៧៧ ៦៨ ៧០, ០៩៦ ៥៥៥៥ ៣៦២, ០៧៨ ៥៥៥៥ ១៣ ដែលជនជាប់ចោទ ជាអ្នកប្រើប្រាស់សម្រាប់ធ្វើការងារក្រុមហ៊ុន ពេលជនជាប់ចោទ បានទទួលប្រាក់ពីគេរួចហើយ មិនព្រមយកមកបញ្ចូលក្នុងបញ្ជីរបស់ក្រុមហ៊ុនទេ និងបានគៃបំបាត់យកប្រាក់ចំនួន ១៦,៦៨៦ (មួយម៉ឺន ប្រាំមួយពាន់ ប្រាំមួយរយ ប៉ែតសិបប្រាំមួយ) ដុល្លារអាមេរិក នោះ ទៅប្រើប្រាស់ជាប្រយោជន៍ផ្ទាល់ខ្លួន ។

នាពេលសវនាការ

១-ជនជាប់ចោទឈ្មោះ [redacted] **សូនីតា** ភេទស្រី អាយុ ១៧ឆ្នាំ ឆ្លើយថា៖ ចំពោះបទចោទប្រកាន់ខាងនេះ រូបខ្លួនពិតជាបានប្រព្រឹត្តអំពើរំលោភលើទំនុកចិត្តប្រាកដមែន គឺខ្លួនចាប់ផ្តើមចូលធ្វើការនៅក្នុងឆ្នាំ២០១៧ ដោយមានតួនាទី ជាបេឡា ក្នុងការទទួលបង់រំលោះដីឡូត៍ នៅក្នុងក្រុមហ៊ុនដីឡូត៍ សូ សេត ឯ.ក មានទីស្នាក់ការនៅខេត្តត្បូងឃ្មុំ។ លុះដល់ក្នុងឆ្នាំ ២០១៩ ខ្លួនចាប់ផ្តើមចេះដកប្រាក់ពីក្រុមហ៊ុន ដោយអតិថិជនបានយកប្រាក់មកបង់ដីឡូត៍ ប៉ុន្តែខ្លួនពុំបានយកប្រាក់ដែលអតិថិជនបង់នោះបញ្ចូលក្នុងបញ្ជីគណនេយ្យក្រុមហ៊ុនទេ គឺខ្លួនបានយកប្រាក់នោះទៅប្រើប្រាស់ផ្ទាល់ខ្លួន (មិនដឹងចំនួនប៉ុន្មាន) ហើយនៅពេលគិតបញ្ជីម្តងៗខ្លួនបានយកប្រាក់ពីអតិថិជនផ្សេងទៀតមកដាក់ជំនួស។ បន្ទាប់មកទៀតនៅក្នុងអំឡុងឆ្នាំ២០២១ ទើបខាងក្រុមហ៊ុនបានស្រាវជ្រាវឃើញថា ខ្លួនបានយកប្រាក់ពីក្រុមហ៊ុន ហើយក្រុមហ៊ុន រួចបានបានបញ្ឈប់ពីការងារតែម្តង និងបានឲ្យខ្លួនសងប្រាក់ដែលយកនោះទៅឲ្យក្រុមហ៊ុនវិញ។ នាងខ្ញុំមិនដឹងថា យកប្រាក់ពីក្រុមហ៊ុនប៉ុន្មាននោះទេ តែខ្លួនទទួលស្គាល់ដែលក្រុមហ៊ុនអះអាងថា ខ្លួនបានយកប្រាក់ចំនួន ១៦,៦៨៦ (មួយម៉ឺន ប្រាំមួយពាន់ ប្រាំមួយរយ ប៉ែតសិបប្រាំមួយ) ដុល្លារអាមេរិក ហើយខ្លួនក៏បានព្រមព្រៀងគ្នាជាមួយក្រុមហ៊ុនក្នុងការសងប្រាក់ ដោយខ្លួនបានបង់ប្រាក់សងចំនួន ៣.៥០០ ដុល្លារអាមេរិក និងខ្លួនត្រូវសងប្រាក់ទៅឲ្យក្រុមហ៊ុនជាបន្តបន្ទាប់ទៀតជារៀងរាល់ខែទៅតាមលក្ខខណ្ឌនោះផងដែរ។ ខ្លួនសូមបញ្ជាក់ថា នៅពេលដែលខ្លួនធ្វើការនៅក្នុងក្រុមហ៊ុន គឺខាងក្រុមហ៊ុនតម្រូវឲ្យមានការគិតបញ្ជីជាប្រចាំថ្ងៃ ប្រចាំខែ និងប្រចាំឆ្នាំ ហើយក្នុង

ការគិតបញ្ជី គឺរូបខ្លួនជាគិតបញ្ជីនោះ ហើយរាល់ការបិទបញ្ជីមានការខុសឆ្គង៣ ទៅ៤ដង ដងដែរ បន្ទាប់ពីបិទបញ្ជីរួចមកខ្លួនត្រូវយកបញ្ជីនេះ ទៅឲ្យខាងគណេយ្យធ្វើបន្ត។

២-អំណានចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ឈ្មោះ [redacted]**វណ្ណា** បានឆ្លើយនៅក្នុងដំណាក់កាលមន្ត្រីនគបាលយុត្តិធម៌ ដំណាក់កាលអយ្យការ និងដំណាក់កាលចៅក្រមស៊ើបសួរ មានភាពស៊ីសង្វាក់គ្នាថា៖ កាលពីអំឡុងឆ្នាំ ២០២១ ក្រុមហ៊ុនសម្គាល់ឃើញថា ក្រុមហ៊ុនបានបាត់ចំណូលពីការបង់រំលោះប្រាក់ថ្លៃដីរបស់អតិថិជន ចំនួន ១៥០០ ដុល្លារអាមេរិក ហើយចំពោះកិច្ចការទទួលប្រាក់ថ្លៃបង់រំលោះដីឡូត៍ពីអតិថិនជ គឺជាការងាររបស់ឈ្មោះ [redacted] សូនីតា។ ក្រោយមកក្រុមហ៊ុនក៏បានសាកសួរឈ្មោះ [redacted] សូនីតា ហើយឈ្មោះ [redacted] សូនីតា បានទទួលស្គាល់ថាខ្លួនជាអ្នកយកប្រាក់ចំនួន ១៥០០ ដុល្លារអាមេរិក នោះ ហើយឈ្មោះ [redacted] សូនីតា ក៏បានសន្យាសងប្រាក់ខាងលើវិញ។ ក្រោយមកខាងក្រុមហ៊ុនក៏បានបញ្ឈប់ការងារឈ្មោះ [redacted] សូនីតា តែម្តង។ លុះដល់អំឡុងឆ្នាំ ២០២១ ក្រុមហ៊ុន បានធ្វើការទូទាត់បញ្ជីចំណូលចំណាយ។ បន្ទាប់មកក្រុមហ៊ុនបានរកឃើញថា ក្រុមហ៊ុនបានបាត់ប្រាក់ ដែលជាប្រាក់ដែលអតិថិជនបង់រំលោះថ្លៃដីប្រចាំខែ ចំនួន ១៦៦៨៦ ដុល្លារអាមេរិក រួមទាំងប្រាក់ខាងលើផងដែរ។ ក្រុមហ៊ុនក៏បានដាក់ការសង្ស័យទៅលើឈ្មោះ [redacted] សូនីតា ម្តងទៀត។ ក្រុមហ៊ុនក៏បានហៅឈ្មោះ [redacted] សូនីតា មកជួបតែឈ្មោះ [redacted] សូនីតា មិនបានមកជួបនោះទេ។ បន្ទាប់មកទៀត ក្រុមហ៊ុនក៏បានដាក់ពាក្យបណ្តឹងទៅស្នងការនគរបាលខេត្តត្បូងឃ្មុំ ហើយឈ្មោះ [redacted] សូនីតា បានឆ្លើយសារភាពថា រូបគេជាអ្នកយកប្រាក់ខាងលើនោះមែន។ ខ្លួនសូមទាមទារសំណងនៃការខូចខាតចំនួន ១៦៦៨៦ ដុល្លារអាមេរិក និងទាមទារសំណងដំងឹចិត្ត **ចំនួន ៣០.០០០ ដុល្លារអាមេរិក**។

៣-ចម្លើយសាក្សីឈ្មោះ [redacted]**ស្រីអូន** ភេទស្រី អាយុ ២៥ឆ្នាំ ឆ្លើយថា៖ នាងខ្ញុំស្គាល់ឈ្មោះ [redacted] សូនីតា ក្នុងឆ្នាំ២០១៩ គាត់ធ្វើការក្នុងក្រុមហ៊ុនលក់ដីឡូត៍ សូ សេត ដែលមានទីស្នាក់ការនៅភូមិទន្លេបិទលើ ឃុំទន្លេបិទ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ គឺកាលពីអំឡុងឆ្នាំ ២០២១ ហើយខ្លួនក៏បានធ្វើការនៅក្នុងក្រុមហ៊ុននោះដងដែរ តែមានទីស្នាក់ការខុសគ្នា។ ខ្លួនបានដឹងតាមរយៈឈ្មោះ [redacted] វណ្ណា (ប្រធានក្រុមហ៊ុនដីឡូត៍) ថាឈ្មោះ [redacted] សូនីតាបានទទួលប្រាក់បង់រំលោះដីឡូត៍ពីអតិថិជនម្នាក់ ប៉ុន្តែមិនបានបញ្ចូលទៅក្នុងក្រុមហ៊ុននោះទេ។ បន្ទាប់មកទៀតក្រុមហ៊ុនបានឲ្យឈ្មោះ [redacted] សូនីតា សងប្រាក់ទៅឲ្យក្រុមហ៊ុន ហើយឈ្មោះ [redacted] សូនីតា បានសងតាមការទាមទាររបស់ក្រុមហ៊ុន។ ពេលនោះក្រុមហ៊ុនក៏បានបញ្ឈប់ឈ្មោះ [redacted] សូនីតា ពីការងារនៅក្នុងអំឡុងខែមេសា ឆ្នាំ២០២១។ លុះដល់ខែឧសភា ខាងក្រុមហ៊ុនក៏បានធ្វើការស្រាវជ្រាវបន្ថែម ក៏បានរកឃើញថា ឈ្មោះ [redacted] សូនីតា បានយកប្រាក់ពីក្រុមហ៊ុនចំនួណ ១៦៦៨៦ ដុល្លារអាមេរិក។ ក្រោយមកទៀតខាងក្រុមហ៊ុនក៏បានហៅឈ្មោះ [redacted] សូនីតា មកដោះស្រាយអំពីរឿងនេះ ក្រៅពីនេះខ្លួនពុំដឹងអ្វីទៀតនោះទេ។

៤-សាក្សីឈ្មោះ [redacted] **ធាវី** បានឆ្លើយនៅក្នុងដំណាក់កាលមន្ត្រីនគបាលយុត្តិធម៌ និងដំណាក់កាលអយ្យការ មានភាពស៊ីសង្វាក់គ្នាថា៖ ខ្លួនបំរើសការងារផ្នែកគណនេយ្យ នៅក្នុងក្រុមហ៊ុន សូ សេត ឯ.ក ដែលមានទីតាំងស្ថិតនៅភូមិទន្លេបិទលើ ឃុំទន្លេបិទ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ ហើយពាក់ព័ន្ធនិងករណីរបស់ឈ្មោះ [redacted] សូនីតា ភេទស្រី ដែលក្រុមហ៊ុនបានដាក់ពាក្យបណ្តឹងប្តឹងថាបានលួចដកប្រាក់របស់ក្រុមហ៊ុន គឺនាងខ្ញុំសូមបញ្ជាក់ថា ឈ្មោះ [redacted] សូនីតា ជាបុគ្គលិកបំរើការងារផ្នែកបេឡា (ស្នាក់ការទន្លេបិទ) ជាមួយរូបនាងខ្ញុំ ។ ក្នុងពេលដែលឈ្មោះ [redacted] សូនីតា បំរើការងារនៅក្នុងក្រុមហ៊ុន គឺរូបគាត់បានទទួលប្រាក់បង់រំលោះថ្លៃដីពីអតិថិជនដែលទិញដីឡូត៍គឺនៅស្នាក់ការទន្លេបិទ និងខេត្តត្បូងឃ្មុំ ក្រោយមកឃើញថាអតិថិជនទូទាត់ប្រាក់មកឲ្យក្រុមហ៊ុនយឺតយ៉ាវ ឈ្មោះ [redacted]ភ័ឌី ជានាយករដ្ឋប្រតិបត្តិ បានទាក់ទង់ទៅ អតិថិជនផ្ទាល់ ពេលនោះអតិថិជនបានប្រាប់ថា ពួកគាត់បានបង់ប្រាក់រួចរាល់ហើយទៅឲ្យឈ្មោះ [redacted] សូនីតា តាមរយៈវីង ។ ក្រោយមកខាងក្រុមហ៊ុនបានហៅឈ្មោះ [redacted] សូនីតា មកដោ

ស្រាយជាមួយក្រុមហ៊ុន ឈ្មោះ [redacted] សូនីតា ក៏បាន យកប្រាក់នោះមកទូទាត់ឲ្យខាងក្រុមហ៊ុនវិញគ្រប់ចំនួន ។ លុះក្រោយមកខាងស្នាក់ការខាងខេត្តត្បូងឃ្មុំ ក៏បានស្រាវជ្រាវ ឃើញថាឈ្មោះ [redacted] សូនីតា មិនបានបញ្ចូលប្រាក់ដែលអតិថិជនបានបង់ចូលទៅក្នុងបញ្ជីរចំណូលរបស់ក្រុមហ៊ុននោះទេ ហើយឈ្មោះ [redacted] សូនីតា មិនបានចូលទៅដោះស្រាយជាមួយក្រុមហ៊ុនទេនៅស្នាក់ការខេត្តត្បូងឃ្មុំទេ ។

៥-តំណាងអយ្យការធ្វើសេចក្តីសន្និដ្ឋាន៖ ក្រោយពីពិភាក្សាដេញដោល ឃើញថា តាមរយៈអង្គហេតុ ភស្តុតាងមាននៅក្នុងសំណុំរឿង និងចម្លើយខាងលើ បង្ហាញឲ្យឃើញថា ពិតជាមានបទល្មើសព្រហ្មទណ្ឌ ដែលប្រព្រឹត្តដោយឈ្មោះ [redacted] **សូនីតា** កាលពីអំឡុងឆ្នាំ២០២១ ប្រាកដមែន។ ដូចនេះ រក្សាបទចោទ ដែលមាននៅក្នុងដីកាសន្និដ្ឋានស្តាពរលេខ ២២១ អយ.ក/២២ ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០២២ របស់តំណាងអយ្យការអមសាលាដំបូងខេត្តត្បូងឃ្មុំទុកជាបានការដដែល និងប្តឹងសុំផ្តន្ទាទោសជនជាប់ចោទទៅតាមនីតិវិធីច្បាប់។

៦-មេធាវីការពារសិទ្ធិរបស់ជនជាប់ចោទធ្វើសេចក្តីសន្និដ្ឋាន៖ ក្រោយពីពិភាក្សាដេញដោល ឃើញថា ក្រោយពីបានពិនិត្យលើឯកសារ និងភស្តុតាងនានាដែលមានក្នុងសំណុំរឿង តាមការសាកសួរនាពេលសវនាការ និងតាមចម្លើយរបស់កូនក្តីនាងខ្ញុំឈ្មោះ [redacted] សូនីតា បានឆ្លើយសារភាពថាចាប់ពីអំឡុងឆ្នាំ២០១៩ ដល់ ឆ្នាំ២០២១ ខ្លួនពិតជាបានដកលុយរបស់ក្រុមហ៊ុនយកមកប្រើប្រាស់ផ្ទាល់ខ្លួនពិតប្រាកដមែន ប៉ុន្តែខ្លួនមិនចាំចំនួន នោះទេ ហើយនៅពេលនេះកូនក្តីនាងខ្ញុំបានដឹងនូវកំហុស និងមិនបានគេចវេះពីការទទួលខុសត្រូវនោះទេ ដោយកូនក្តីនាងខ្ញុំបានសងប្រាក់ទៅក្រុមហ៊ុនវិញជាបន្តបន្ទាប់ចាប់តាំងពីថ្ងៃទី០១ ខែមេសា ឆ្នាំ២០២២ រហូតមកដល់ថ្ងៃទី០៨ ខែសីហា ឆ្នាំ២០២២ សងបានចំនួន ៣៥០០ ដុល្លារអាមេរិក ហើយ។ មួយវិញទៀត នៅពេលប្រព្រឹត្តបទល្មើសកូនក្តីរបស់នាងខ្ញុំ មិនទាន់មានអាយុគ្រប់ ១៨ឆ្នាំ ពេញបរិបូណ៌នៅឡើយ ដោយតាមសំបុត្របញ្ជាក់កំណើត ចុះថ្ងៃទី ១៥ ខែមេសា ឆ្នាំ ២០០៥ របស់មេឃុំក្រឡា បានបញ្ជាក់ថា ឈ្មោះ [redacted] សូនីតា កើតនៅថ្ងៃទី១០ ខែមេសា ឆ្នាំ២០០៣។ សំណូមពរ សូមលោកប្រធានក្រុមប្រឹក្សាជំនុំជម្រះ មេត្តាពិចារណាសម្រេចបន្ធូរបន្ថយទោសដល់កូនក្តីរបស់នាងខ្ញុំ តាមបញ្ញត្តិមាត្រា១៦០ នៃក្រមព្រហ្មទណ្ឌ ដោយក្តីអនុគ្រោះ។

៧-សម្តីចុងក្រោយរបស់ជនជាប់ចោទឈ្មោះ [redacted] **សូនីតា** បានឆ្លើយថា៖ ខ្លួនបានដឹងអំពីកំហុសហើយ សូមតុលាការជួយបន្ធូរបន្ថយទោសដល់រូបខ្លួន ខ្លួនសន្យាថាឈប់ប្រព្រឹត្តអំពើបែបនេះតទៅទៀតហើយ។

-ក្រោយពី បានស្តាប់ចម្លើយរបស់ជនជាប់ចោទ, ដើមបណ្តឹង និងសាក្សី
-ក្រោយពី បានស្តាប់សេចក្តីសន្និដ្ឋាន និងការប្តឹងសុំរបស់តំណាងអយ្យការ
-ក្រោយពី បានស្តាប់សេចក្តីសន្និដ្ឋាន របស់មេធាវីការពារសិទ្ធិជនជាប់ចោទ
-ក្រោយពី បានពិនិត្យលើឯកសារភស្តុតាងនានា
-ក្រោយពី បានពិនិត្យពិភាក្សា និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

<u>សំអាងហេតុ</u>

១/ កាលពីអំឡុងឆ្នាំ២០១៧ ជនជាប់ចោទ**ឈ្មោះ** [redacted] **សូនីតា** បានចូលមកធ្វើការនៅ ក្នុងក្រុមហ៊ុនលក់ដីឡូត៍ សូ សេត ឯ.ក ដែលមានស្នាក់ការនៅភូមិទន្លេបិទលើ ឃុំទន្លេបិទ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ ដោយធ្វើការផ្នែកបេឡា ហើយជនជាប់ចោទ គឺជាអ្នកទទួលប្រាក់បង់រំលោះថ្លៃដីពីអតិថិជន ។ ក្រោយមកក្រុមហ៊ុនមានការសង្ស័យពីការបាត់ទឹកប្រាក់ដែលអតិថិជនបានបង់ ហើយខាងក្រុមហ៊ុនក៏បានធ្វើការស្រាវជ្រាវរកឃើញថា មានអតិថិជន ចំនួន ១៨នាក់ ដែលបង់រំលោះថ្លៃទិញដីឡូត៍ពីក្រុមហ៊ុន តាមរយៈលេខទូរស័ព្ទរបស់ក្រុមហ៊ុន ចំនួន ០៣ខ្សែ ០៨៨ ៧៧៧ ៦៨ ៧០, ០៩៦ ៥៥៥៥ ៣៦២, ០៧៨ ៥៥៥៥ ១៣ ដែលជនជាប់ចោទ ជាអ្នកប្រើប្រាស់សម្រាប់ធ្វើការងារក្រុមហ៊ុន ពេលជនជាប់ចោទ បានទទួលប្រាក់ពីគេរួចហើយ មិនព្រមយកមកបញ្ចូលក្នុងបញ្ជីរបស់ក្រុមហ៊ុនទេ និងបាន

Scanned with CamScanner

គែបំបាត់យកប្រាក់ចំនួន **១៦,៦៨៦** (**មួយម៉ឺន ប្រាំមួយពាន់ ប្រាំមួយរយ ប៉ែតសិបប្រាំមួយ**) **ដុល្លារអាមេរិក** នោះទៅប្រើប្រាស់ជាប្រយោជន៍ផ្ទាល់ខ្លួន ។

២/ អង្គហេតុ និងសកម្មភាពរបស់ជនជាប់ចោទ ដែលបានប្រព្រឹត្តនៅ ភូមិទន្លេបិទលើ ឃុំទន្លេបិទ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ កាលពីថ្ងៃទី០១ ខែមេសា ឆ្នាំ២០២១ ខាងលើនេះ គឺជាបទល្មើសព្រហ្មទណ្ឌ **រំលោភលើទំនុកចិត្ត** បទល្មើសព្រហ្មទណ្ឌដែលមានចែង និងបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា ៣៩១ និងមាត្រា ៣៩២ នៃក្រមព្រហ្មទណ្ឌ។

៣/ ជនជាប់ចោទ [redacted] **សូនីតា** ឆ្លើយថាសារភាព ចំពោះបទចោទប្រកាន់ខាងនេះ រូបខ្លួនពិតជាបានប្រព្រឹត្តរំលោភលើទំនុកចិត្តប្រាកដមែន ដោយបានគែបំបាត់ប្រាក់ក្រុមហ៊ុន ចំនួន **១៦,៦៨៦** (**មួយម៉ឺន ប្រាំមួយពាន់ ប្រាំមួយរយ ប៉ែតសិបប្រាំមួយ**) **ដុល្លារអាមេរិក** ។ គឺខ្លួនចាប់ផ្តើមចូលធ្វើការនៅក្នុងឆ្នាំ២០១៧ ដោយមានតួនាទី ជាបេឡាក្នុងការទទួលបង់រំលោះដីឡូត៍ នៅក្នុងក្រុមហ៊ុនដីឡូត៍ សូ សេត ឯ.ក មានទីស្នាក់ការទន្លេបិទ ខេត្តត្បូងឃ្មុំ។ លុះដល់ក្នុងឆ្នាំ ២០១៩ ខ្លួនចាប់ផ្តើមចេះដកប្រាក់ពីក្រុមហ៊ុន ដោយអតិថិជនបានយកប្រាក់មកបង់ដីឡូត៍ ប៉ុន្តែខ្លួនពុំបានយកប្រាក់ដែលអតិថិជនបង់នោះបញ្ចូលក្នុងបញ្ជីគណនេយ្យក្រុមហ៊ុនទេ គឺខ្លួនបានយកប្រាក់នោះទៅប្រើប្រាស់ផ្ទាល់ខ្លួន (មិនដឹងចំនួនប៉ុន្មាន) ហើយនៅពេលគិតបញ្ជីម្តងៗខ្លួនបានយកប្រាក់ពីអតិថិជនផ្សេងទៀតមកដាក់ជំនួស។ ខ្លួនបានដឹងអំពីកុំហុស និងបានសងប្រាក់រំលោះប្រចាំខែឲ្យក្រុមហ៊ុនវិញហើយ សូមតុលាការជួយបន្ធូរបន្ថយទោសដល់រូបខ្លួន ខ្លួនសន្យាថាឈប់ប្រព្រឹត្តអំពើបែបនេះតទៅទៀតហើយ។ ហេតុដូច្នេះ គប្បីតុលាការពិនិត្យ និងសម្រេចផ្តន្ទាទោស តាមនីតិវិធីច្បាប់ ។

៤/ យោងចម្លើយ ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី/ជនរងគ្រោះ សាក្សី និងភស្តុតាងឯកសារផ្សេងៗក្នុងសំណុំរឿង គឺមានភាពស៊ីសង្វាក់គ្នា ដែលបង្ហាញឲ្យឃើញពី **ពិរុទ្ធភាព** របស់ជនជាប់ចោទពី **<u>បទ</u>: រំលោភលើទំនុកចិត្ត** ប្រព្រឹត្តនៅភូមិទន្លេបិទលើ ឃុំទន្លេបិទ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ កាលពីថ្ងៃទី០១ ខែមេសា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា ៣៩១ និងមាត្រា ៣៩២ នៃក្រមព្រហ្មទណ្ឌ។

៥/ អង្គហេតុនៃអំពើ **រំលោភលើទំនុកចិត្ត** នេះជនជាប់ចោទជាអនីតិជនខ្លះការយល់ដឹងមិនមានការពិចារណាវែងឆ្ងាយ ក៏កើតឲ្យមានការយកប្រាក់ពីក្រុមហ៊ុនដោយពុំបានគិតគូឲ្យដិតដល់ ហើយជនជាប់ចោទរូបនេះទទួលស្គាល់នូវកំហុសរបស់ខ្លួនមិនបង្កភាពស្មុកស្មាញនៅក្នុងនីតិវិធីគ្រប់ដំណាក់កាល និងបានសងប្រាក់រំលោះប្រចាំខែឲ្យក្រុមហ៊ុនវិញហើយ ។ ដូច្នេះគប្បីតុលាការ លើកយកផ្នែកទី២ ស្តីពីការព្យួរទោសធម្មតា នៃក្រមព្រហ្មទណ្ឌ មកធ្វើការពិចារណា ។

៦/ ជនជាប់ចោទ ជាអនីតិជន គិតត្រឹមថ្ងៃប្រព្រឹត្តបទល្មើសមានអាយុ ១៧ ឆ្នាំ ១១ ខែ ២១ ថ្ងៃ ហេតុដូច្នេះគប្បី តុលាការលើកយកមាត្រា១៦០ នៃក្រមព្រហ្មទណ្ឌ (មូលទោសអនុវត្តចំពោះអនីតិជនអាយុចាប់ពី១៤ឆ្នាំឡើងទៅ) នៃក្រមព្រហ្មទណ្ឌ មកពិនិត្យ និងសម្រេច តាមនីតិវិធីច្បាប់ ។

៧/ ដើមបណ្តឹងរដ្ឋប្បវេណី **ឈ្មោះ [redacted] វណ្ណា** បានទាមទារប្រាក់ដែលជនជាប់ចោទបានគែបំបាត់ ចំនួន **១៦.៦៨៦** (**មួយម៉ឺន ប្រាំមួយពាន់ ប្រាំមួយរយ ប៉ែតសិបប្រាំមួយ**) **ដុល្លារអាមេរិក** និងជម្ងឺចិត្ត **ចំនួន ៣០.០០០** (**បីម៉ឺន**) **ដុល្លារអាមេរិក**។ ហេតុដូច្នេះ គប្បីតុលាការពិចារណា និងសម្រេច តាមការខូចខាត ព្យសនកម្មជាក់ស្តែង និងដោយគិតពិចារណាអំពីកាល:ទេស:ជុំវិញផ្សេងៗ ។

៨/ អំពើល្មើសរបស់ជនជាប់ចោទ បង្ករឲ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់ របៀបរៀបរយ និងសន្តិសុខល្អក្នុងសង្គម ហេតុដូច្នេះ គប្បី តុលាការសម្រេចផ្តន្ទាទោសជនជាប់ចោទតាមច្បាប់ ។

ហេតុដូច្នេះតិន្តិច្ឆ័យសេចក្តី

១/ ផ្តន្ទាទោសលើជនជាប់ចោទ៖

. **ឈ្មោះ [redacted] សូនីតា** (មានសាវតារជាតិដូចខាងលើ) ជាក់ពន្ធនាគារ **ចំនួន ០៦** (**ប្រាំមួយ**) **ខែ ប៉ុន្តែទោសនេះ ត្រូវអនុវត្តទោសព្យរធម្មតា និងពិន័យជាប្រាក់ ចំនួន ១.០០០.០០០** (**មួយលាន**) **រៀល** ។

ពីបទ៖ រំលោភលើទំនុកចិត្ត ប្រព្រឹត្តនៅ ភូមិទន្លេបិទលើ ឃុំទន្លេបិទ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ កាលពីថ្ងៃទី០១ ខែ មេសា ឆ្នាំ២០២១ ស្របតាមមាត្រា ៣៩១ និងមាត្រា ៣៩២ នៃក្រមព្រហ្មទណ្ឌ។

២/ បង្គាប់ឲ្យជនជាប់ចោទ៖

. **ឈ្មោះ [redacted] សូនីតា** សងប្រាក់ដែលបានគៃបំបាត់ សំណងការខូចខាត និងជម្ងឺចិត្តទៅឲ្យដើមបណ្តឹងរដ្ឋប្បវេណី **ឈ្មោះ [redacted] វណ្ណា** ជាប្រាក់សរុប **ចំនួន ១៧.០០០** (**មួយម៉ឺន ប្រាំពីរពាន់**) **ដុល្លាអាមេរិក** ការទាមទារលើសពីនេះ សម្រេចច្រានចោល ។

សាលក្រមនេះ ជំនុំជម្រះ និងប្រកាសជាសាធារណៈ ចំពោះមុខពិរុទ្ធជន និងកំចាំងមុខ ដើមបណ្តឹងរដ្ឋប្បវេណី ទុកសិទ្ធិប្តឹងទាស់ និងឧទ្ធរណ៍តាមកំណត់ច្បាប់។

ថ្ងៃពុធ ៥កើត ខែភទ្របទ ឆ្នាំ ខាល ចត្វាស័ក ព.ស២៥៦៦
ខេត្តត្បូងឃ្មុំ ,ថ្ងៃទី៣១ ខែ សីហា ឆ្នាំ ២០២២

ក្រឡាបញ្ជីសវនាការ	**ចៅក្រមប្រឹក្សា**	**ចៅក្រមប្រឹក្សា**	**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**
ហត្ថលេខា និងត្រា៖	ហត្ថលេខា៖ [redacted]		ហត្ថលេខាង និងត្រា៖
- ហ [redacted]			[redacted]

បានថតចម្លងចេញត្រឹមត្រូវពីច្បាប់ដើម។
ថ្ងៃពុធ ៥កើត ខែភទ្របទ ឆ្នាំ ខាល ចត្វាស័ក ព.ស២៥៦៦
ខេត្តត្បូងឃ្មុំ ,ថ្ងៃទី៣១ ខែ សីហា ឆ្នាំ ២០២២

បានឃើញ
ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

[redacted]

ក្រឡាបញ្ជី

[redacted]

Scanned with CamScanner